**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៥៧៤៥......សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការអនុញ្ញាតឲ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣/១៣៩៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាល និងកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ១១១/១៦ ក.អ.ជ.ប្រក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ របស់ ក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការតែងតាំងមន្ត្រីខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- យោងសំណើរបស់លោកអ៊ុក ពញ្ញា ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីសំណើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១ ៈ-**

ត្រូវបានអនុញ្ញាតឱ្យលោក អ៊ិត ពេញ្ញា អត្តលេខ ១៨៤១២០០១៤៧ អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ច អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីបំពេញមុខតំណែងជានាយកខុទ្ទល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ រហូតដល់ចប់ភារកិច្ចឬនៅពេលលាឈប់ពីមុខតំណែង ។

**ប្រការ២ ៈ-**

ក្របខ័ណ្ឌលោក អ៊ិត ពេញ្ញា ត្រូវរក្សាទុកនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឡែកបៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំ នៃបៀវត្ស ត្រូវផ្ទេរទៅក្រសួងអភិវឌ្ឍន៍ជនបទ។

**ប្រការ៣ ៈ-**

នៅពេលចប់ភារកិច្ច សាមីខ្លួនត្រូវដាក់ពាក្យសុំចូលបម្រើការងារ និងផ្ទេរបៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ។

**ប្រការ៤ ៈ-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងអភិវឌ្ឍន៍ជនបទ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ